ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE 柬 捕 寨 大 众 伦 平 保 险

# យើងខ្ញុំធានារ៉ាប់រងលោកអ្នក ក្នុងប្រទេសកម្ពុជា

## កិច្ចសន្យាធានារ៉ាប់រងរូបិយវត្ថុ

ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេវាកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាសរសេរលិខិតមកក្រុមទទួលពាក្យបណ្តឹងរបស់យើងខ្ញុំ :


| | | |
|---|---|---|
| អាសយដ្ឋានទំនាក់ទំនង | : | **ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី**<br>ជាន់ទី៧ នៃអគារកម្ពុប៊ែង<br>ផ្ទះលេខ ២៣ ផ្លូវ ១១៤<br>សង្កាត់ផ្សារថ្មី ២<br>ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា<br>ប្រអប់សំបុត្រ ១៥៥៦ |
| លេខទូរស័ព្ទ | : | + ៨៥៥ ២៣ ៩៦៦ ៩៦៦ / ៩៩៨ ២០០ / ៩៨៦ ២៧៩ |
| លេខទូរសារ | : | + ៨៥៥ ២៣ ៩៨៦ ៣០៨ / ២៧៣ |
| អ៊ីមែល | : | complaint@campulonpac.com.kh |
| គេហទំព័រ | : | www.campulonpac.com.kh |


**ក្នុងករណីមានឧប្បត្តិហេតុកើតឡើង**

**លេខទូរសព្ទ័ប្រចាំការ២៤ម៉ោង**

+ ៨៥៥ ១៦ ៨១០ ៩៩៩ / ៨២០ ៩៩៩

+ ៨៥៥ ១៧ ៧៩៩ ៩០២ / ៧៩៩ ៩០៣

អ៊ីមែល : claims@campulonpac.com.kh

<u>សំគាល់:</u>

ក្នុងករណីមានវិវាទកើតឡើង ឬការខុសឆ្គងអត្ថន័យណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ នោះក្រុមហ៊ុនធានារ៉ាប់រងយើងខ្ញុំនឹងយកកិច្ចសន្យាធានារ៉ាប់រងជាភាសាអង់គ្លេសជាសំអាង ។

យើងខ្ញុំសូមស្នើជាពិសេសថា សូមលោកអ្នកអានកិច្ចសន្យាធានារ៉ាប់រងនេះអោយបានហ្មត់ចត់ និងផ្ញើត្រឡប់មកកាន់ក្រុមហ៊ុនយើងខ្ញុំវិញភ្លាម ប្រសិនបើមានភាពចាំបាច់ត្រូវកែតម្រូវ ។

## កិច្ចសន្យាធានារ៉ាប់រងរូបិយវត្ថុ

**ដោយហេតុថា** បុគ្គលដែលត្រូវបានធានារ៉ាប់រង ដែលមានឈ្មោះនៅក្នុងតារាងឧបសម្ព័ន្ធនៃកិច្ចសន្យាធានារ៉ាប់រងនេះ បានធ្វើសំណើ និងសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជ្ជាប៉ាក ភីអិលស៊ី ( តទៅនេះហៅកាត់ថា "ក្រុមហ៊ុន" ) ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងបានយល់ព្រមនឹងត្រូវបានចាត់ទុកថាមានលក្ខណៈជាកិច្ចសន្យា និងមានសុពលភាព និងជាមូលដ្ឋាននៃកិច្ចសន្យានេះ បានបង់ ឬយល់ព្រមបង់បុព្វលាភធានារ៉ាប់រង ដូចបានចែងក្នុងតារាងឧបសម្ព័ន្ធបានបញ្ជាក់ជូនខាងលើ ដើម្បីទទួលបានសំណងដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

**ដោយហេតុនេះ កិច្ចសន្យានេះផ្តល់នូវសក្ខីកម្មដែលបញ្ជាក់ថា** ដោយផ្អែកលើ ខ ចែង ករណីលើកលែង ដែនកំណត់ និងលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ឬមានចែងនៅក្នុងបដិលេខបន្ថែម ក្រុមហ៊ុននឹងផ្តល់សំណងដល់បុគ្គលដែលត្រូវបានធានារ៉ាប់រងលើ :

ការបាត់បង់ប្រាក់ ដែលមានន័យថា ការបាត់បង់សាច់ប្រាក់សុទ្ធ (Cash) ធនបត្រ (Currency Notes) ក្រដាសប្រាក់ (Bank Notes) មូលប្បទានបត្រ (Cheques) ប័ណ្ណផ្ញើប្រាក់តាមរយៈប្រៃសណីយ៍ (Potal Orders or Money Orders) ដោយសារតែមូលហេតុណាមួយក៏ដោយ ដែលមិនត្រូវបានលើកលែងនៅក្នុងស្ថានភាពទាំងឡាយដែលត្រូវបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធដូចមានភ្ជាប់នឹងកិច្ចសន្យាធានារ៉ាប់រងនេះ ដែលកើតឡើងជាក់ស្តែងក្នុងអំឡុងពេលនៃការធានារ៉ាប់រង ដូចមានចែងក្នុងឧបសម្ព័ន្ធខាងលើ ឬក្នុងអំឡុងពេលបន្តទៀតណាមួយដែលក្រុមហ៊ុនអាចព្រមទទួលយកការបង់ប្រាក់សម្រាប់ការបន្តកិច្ចសន្យាធានារ៉ាប់រងនេះ ។

## ករណីលើកលែង

កិច្ចសន្យាធានារ៉ាប់រងនេះ មិនផ្តល់សំណងដល់បុគ្គលដែលត្រូវបានធានារ៉ាប់រង លើការបាត់បង់ :

១. ដែលកើតឡើងដោយសារតែការក្លែងបន្លំ ឬភាពមិនស្មោះត្រង់នៃនិយោជិតរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

២. ដោយសារតែកំហុសដែលកើតឡើងក្នុងពេលបំពេញការងារ ឬកំហុសផ្នែកគណនេយ្យ ។

៣. ដោយសារតែស្ថានភាពដែលមិនអាចពន្យល់បកស្រាយបាន ។

៤. ដែលត្រូវបានធានារ៉ាប់រង (សម្រាប់អត្ថិភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងផ្សេងទៀត) ដោយកិច្ចសន្យាធានារ៉ាប់រងលើការបាត់បង់ផ្នែកហិរញ្ញវត្ថុដោយសារភាពមិនស្មោះត្រង់របស់និយោជិតណាមួយ ។

៥. ដោយសារតែការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុ ។

៦. ពីយានយន្តដែលគ្មានការការពារ ឬយាមកាម ។

៧. ការខាតបង់ផ្នែកហិរញ្ញវត្ថុគ្រប់ប្រភេទ ។

៨. ប្រាក់ដែលដកចេញពីទូដែក/ថតតុ/ទូ បន្ទាប់ពីមានការប្រើប្រាស់កូនសោនៃទូដែក/ថតតុ/ទូ ឬកូនសោចម្លងនៃទូដែក/ថតតុ/ទូទាំងនោះ ដែលជាកម្មសិទ្ធិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង លើកលែងតែកូនសោទាំងនោះ ត្រូវបានទទួលដោយការគំរាមកំហែង ឬអំពើហិង្សា និងក្នុងលក្ខខណ្ឌថា ទូដែក/ថតតុ/ទូទាំងនោះ ត្រូវបានចាក់សោជាប់ លើកលែងតែនៅពេលមានការប្រើប្រាស់បន្ទាន់ភ្លាមៗ ។

៩. កើតឡើងដោយផ្ទាល់ ឬដោយប្រយោល នៅក្បែរ ឬពីចម្ងាយ កើតឡើងដោយ ឬត្រូវបានរួមចំណែកបង្កឡើងដោយ ឬអាចត្រូវបានរកឃើញថាកើតឡើងដោយ ឬកើតឡើងពី ឬពាក់ព័ន្ធនឹងទង្វើឈ្លានពានរបស់សត្រូវបរទេស ប្រតិបត្តិការសង្គ្រាម (ទោះបីជាមាន ឬមិនមានការប្រកាសសង្គ្រាមក៏ដោយ) សង្គ្រាមស៊ីវិល កូដកម្ម កុប្បកម្ម ការរំជើបរំជួលរបស់សង្គម សង្កុបកម្ម អំពើឧទ្ទាម បដិវត្តន៍ អំពើបះបោរ ការប្រើអំណាចយោធា ឬការដណ្តើមអំណាច ឬដោយសារតែលទ្ធផលផ្ទាល់ ឬប្រយោលនៃការកើតឡើងសកម្មភាពទាំងនេះណាមួយ និងក្នុងករណីមានបណ្តឹងទាមទារណាមួយកើតឡើងយោងតាមតាមកិច្ចសន្យាធានារ៉ាប់រងនេះ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវបញ្ជាក់អះអាងថា ការបាត់បង់ ឬការខូចខាតនោះ បានកើតឡើងដោយឯកឯង ហើយគ្មានទាក់ទងនឹង ឬកើតឡើងម្តងម្កាលដោយ ឬត្រូវបានរួមចំណែកបង្កឡើងដោយ ឬអាចត្រូវបានរកឃើញថាកើតឡើងដោយសារតែការកើតឡើងនៃសកម្មភាពទាំងនោះណាមួយ ឬជាលទ្ធផលនៃសកម្មភាពទាំងនោះ ហើយបើសិនខ្វះ ឬគ្មានការបញ្ជាក់អះអាងបែបនោះទេ ក្រុមហ៊ុននឹងមិនទទួលខុសត្រូវផ្តល់ការទូទាត់សំណងពាក់ព័ន្ធនឹងការទាមទារនោះឡើយ ។

១០. ឬក៏ការចំណាយណាមួយក៏ដោយដែលជាលទ្ធផលនៃ ឬកើតឡើងដោយសារតែសកម្មភាពទាំងនោះ ឬការបាត់បង់ផ្នែកហិរញ្ញវត្ថុដោយសារតែការអាក់ខាននៃប្រតិបត្តិការអាជីវកម្មដោយផ្ទាល់ ឬដោយប្រយោល ឬត្រូវបានរួមចំណែកបង្កឡើងដោយ ឬកើតឡើងមកពីការភាយចំហាយជាតិវិទ្យុសកម្ម ឬការចម្លងមេរោគដោយវិទ្យុសកម្មពីឥន្ទនៈនុយក្លេអ៊ែរណាមួយ ឬពីកាកសំណល់នុយក្លេអ៊ែរដែលបានមកពីចំហេះឥន្ទនៈនុយក្លេអ៊ែរ ។ សម្រាប់តែគោលបំណងនៃករណីលើកលែងនេះប៉ុណ្ណោះ ចំហេះនឹងរួមបញ្ចូលនូវដំណើរការស្វ័យរក្សានៃការបំបែកអាតូមនុយក្លេអ៊ែរ ។

ការផ្តល់សំណង ឬការទូទាត់សំណងដែលធ្វើឡើងក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ មិនត្រូវអនុវត្តចំពោះ និងមិនត្រូវរួមបញ្ចូលនូវឧបទ្ទវហេតុ ការបាត់បង់ ការបំផ្លិចបំផ្លាញ ឬការខូចខាតណាមួយ ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោល ឬត្រូវបានរួមចំណែកបង្កឡើងដោយ ឬកើតឡើងពីសម្ភារអាវុធនុយក្លេរអ៊ែរឡើយ ។

## លក្ខខណ្ឌនានា

១. ការធានារ៉ាប់រងនេះ មិនអាចចាប់ផ្តើមបានឡើយ រហូតដល់បុព្វលាភធានារ៉ាប់រងត្រូវបានបង់ជាក់ស្តែងឱ្យទៅ និងទទួលដោយក្រុមហ៊ុន ហើយលិខិតទទួលយកជាផ្លូវការ និងកិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុន ត្រូវបានចេញជូន ហើយគ្មានការបង់ប្រាក់ទាក់ទងនឹងបុព្វលាភធានារ៉ាប់រងត្រូវបានចាត់ទុកជាការបង់ប្រាក់ទៅឱ្យក្រុមហ៊ុនឡើយ លុះត្រាតែទម្រង់បោះពុម្ពនៃបង្កាន់ដៃដែលត្រូវបានចុះហត្ថលេខាដោយតំណាងផ្លូវការ ឬដែលត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវរបស់ក្រុមហ៊ុនត្រូវបានចេញជូន ។

២. រាល់ការជូនដំណឹងទាំងអស់ត្រូវបានតម្រូវឱ្យផ្តល់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ជូនក្រុមហ៊ុនចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងផ្ញើទៅកាន់សាខា ឬភ្នាក់ងារក្រុមហ៊ុន ជាទីកន្លែងដែលកិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានចេញជូន ហើយការជូនដំណឹង ឬការយល់ដឹងពីអ្វីមួយពាក់ព័ន្ធនឹងកិច្ចសន្យាធានារ៉ាប់រងនេះ ឬការទាមទារសំណងណាមួយស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ មិនត្រូវបានចាត់ទុកថាជាការជូនដំណឹងទៅកាន់ ឬជាការយល់ដឹងរបស់ក្រុមហ៊ុនឡើយ លុះត្រាតែត្រូវបានផ្តល់ជូន ហើយគ្មានការកែប្រែលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះ និងគ្មានបដិលេខបន្ថែមចំពោះលក្ខខណ្ឌទាំងនោះណាមួយនឹងមានសុពលភាពឡើយ លុះត្រាតែការកែប្រែ ឬបដិលេខដូចគ្នានេះត្រូវបានចុះហត្ថលេខា ឬបញ្ជាក់ដោយតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុន ។

៣. ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ឈប់នៅពេលណាមួយតាមសំណើរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ក្នុងករណីនេះក្រុមហ៊ុននឹងបង្វិលសងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងវិញចំនួនកៅសិបភាគរយ(៩០%) នៃបុព្វលាភធានារ៉ាប់រងដែលនៅសល់សម្រាប់រយៈពេលដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃសុំបញ្ឈប់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយក្នុងលក្ខខណ្ឌថាពុំមានបណ្តឹងទាមទារសំណងណាមួយកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងនេះទេ។ កិច្ចសន្យាធានារ៉ាប់រងនេះក៏អាចត្រូវបានបញ្ឈប់ផងដែរតាមជម្រើសរបស់ក្រុមហ៊ុន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ជាមុនទៅកាន់អាសយដ្ឋានដែលគេស្គាល់ចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងករណីនេះលោកអ្នកមានសិទ្ធិទទួលបានការបង្វិលសងបុព្វលាភមកវិញ តាមសមាមាត្រនៃបុព្វលាភសម្រាប់រយៈពេលដែលនៅមានសុពលភាពគិតចាប់ពីថ្ងៃសុំបញ្ឈប់ការធានារ៉ាប់រង។

   រាល់ការសុំបញ្ឈប់ការធានារ៉ាប់រង លោកអ្នកនឹងពុំត្រូវបានទទួលការបង្វិលសងនូវបុព្វលាភធានារ៉ាប់រងវិញឡើយ ប្រសិនបើបុព្វលាភនោះត្រូវបានបង់ក្នុងកម្រិតអប្បបរមា។

៤. បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវចាត់វិធានការប្រុងប្រយ័ត្ន និងសមហេតុផលទាំងអស់សម្រាប់សុវត្ថិភាពនៃទ្រព្យសម្បត្តិដែលបានធានារ៉ាប់រង ហើយភ្លាមៗបន្ទាប់ពីដឹងព្រឹត្តិការណ៍ណាមួយដែលបណ្តាលអោយ ឬទំនងជាបណ្តាលអោយមានការទាមទារសំណងកើតឡើង ស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះត្រូវ :

   (ក) ជូនដំណឹងដល់មន្ត្រីនគរបាល ក្នុងករណីមានអំពើចោរកម្ម ឬការបាត់បង់ ឬសកម្មភាពឧក្រិដ្ឋ ហើយត្រូវផ្តល់នូវជំនួយសមហេតុផលទាំងអស់ដើម្បីបង្កឱ្យមានការរកឃើញ និងធានាការផ្តន្ទាទោសជនល្មើស និងដើម្បីតាមដាន និងយកមកវិញនូវទ្រព្យសម្បត្តិទាំងនោះ ។

   (ខ) ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនសម្រាប់គ្រប់ករណីទាំងអស់ និងក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីដាក់ការទាមទារសំណងជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមហ៊ុន ត្រូវផ្តល់នូវភស្តុតាងលម្អិតទាំងអស់ និងភិនភាគដែលអាចត្រូវបានតម្រូវដោយសមហេតុផលដោយក្រុមហ៊ុន ។

   (គ) ក្នុងរាល់ករណីទាំងអស់ កំណត់ត្រាពេញលេញនៃចំនួនសាច់ប្រាក់សុទ្ធ ដែលត្រូវបានរក្សាទុកក្នុងទូដែក/ថតតុ/ទូ ត្រូវរក្សាទុកនៅទីកន្លែងផ្សេងទៀត ជាជាងទុកក្នុងទូដែក/ថតតុ/ទូទាំងនោះ ហើយការទទួលខុសត្រូវរបស់ក្រុមហ៊ុន ត្រូវបានកម្រិតត្រឹមចំនួនសាច់ប្រាក់សុទ្ធដូចបានបង្ហាញក្នុងរបាយការណ៍ ដែលត្រូវរក្សាទុកក្នុងទូដែក/ថតតុ/ទូ នៅពេលមានការបាត់បង់ ដោយមិនឱ្យលើសពីចំនួនទឹកប្រាក់គិតជាដុល្លារអាមេរិកទាំងអស់ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធឡើយ ។

៥. ភ្លាមៗបន្ទាប់ពីមានការបាត់បង់រូបិយវត្ថុនៅក្នុងផ្នែកបរិវេណអគារនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដែនកំណត់នៃការទទួលខុសត្រូវយោងតាមផ្នែកនេះត្រូវបានកាត់បន្ថយដោយចំនួនទឹកប្រាក់នៃការបាត់បង់នោះ ហើយដែនកំណត់នៃការទទួលខុសត្រូវដែលត្រូវបានកាត់បន្ថយនោះ គឺជាដែនកំណត់

នៃទំនួលខុសត្រូវថ្មីរបស់ក្រុមហ៊ុនយោងតាមផ្នែកនោះ ក្នុងករណីមានការបាត់បង់ ឬការខូចខាតបន្ថែមទៀតណាមួយ ដែលកើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងបច្ចុប្បន្ន លុះត្រាតែក្រុមហ៊ុនព្រមទទួលយកការបង់ប្រាក់បុព្វលាភធានារ៉ាប់រងបន្ថែម ដើម្បីទទួលបានដែនកំណត់នៃការទទួលខុសត្រូវពេញលេញឡើងវិញ ។

៦. ក្រុមហ៊ុនអាចប្រើមធ្យោបាយផ្លូវច្បាប់ទាំងអស់ នៅពេលណាមួយក៏បានដោយធ្វើការចំណាយផ្ទាល់ខ្លួន ក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងសម្រាប់ការទទួលបានមកវិញនូវទ្រព្យសម្បត្តិណាមួយដែលបាត់បង់ ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារសំណង យោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវផ្តល់នូវជំនួយដោយសមហេតុផលទាំងអស់សម្រាប់គោលបំណងនោះ ។ ទឹកប្រាក់ណាមួយដែលទទួលបានមកវិញ បន្ទាប់ពីសំណងត្រូវបានបង់ជូនស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ ទឹកប្រាក់នោះគឺជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ប៉ុន្តែទោះបីយ៉ាងណាក៏ដោយមិនត្រូវលើសពីចំនួនទឹកប្រាក់ដែលត្រូវបានបង់ដោយក្រុមហ៊ុនពាក់ព័ន្ធនឹងការទាមទារទាំងនោះឡើយ ។

៧. បុព្វលាភធានារ៉ាប់រងស្របតាមកិច្ចសន្យាធានារ៉ាប់រងនេះ និងបុព្វលាភសម្រាប់បន្តការធានារ៉ាប់រងថ្មីទាំងអស់ ដែលអាចត្រូវបានទទួលយកពាក់ព័ន្ធនឹងហានិភ័យនៃការដឹកជញ្ជូនរូបិយវត្ថុ ត្រូវបានកំណត់ដោយចំនួនទឹកប្រាក់ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធដែលត្រូវបានគ្របដណ្តប់ក្នុងអំឡុងពេលនៃការធានារ៉ាប់រងបច្ចុប្បន្ន ។ កំណត់ត្រាដ៏ត្រឹមត្រូវ ត្រូវរក្សាទុកនៅក្នុងសៀវភៅរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង អំពីចំនួនទឹកប្រាក់ទាំងនោះដែលត្រូវដឹកជញ្ជូនដោយមានការធានារ៉ាប់រង។ គ្រប់ពេលវេលាទាំងអស់ បុគ្គលដែលត្រូវបានធានារ៉ាប់រង ត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនត្រួតពិនិត្យសៀវភៅទាំងនោះ ហើយក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់នៃរយៈពេលធានារ៉ាប់រងនីមួយៗ ត្រូវផ្តល់ឱ្យក្រុមហ៊ុននូវរបាយការណ៍គណនេយ្យដ៏ត្រឹមត្រូវអំពីចំនួនទឹកប្រាក់ទាំងអស់ដែលត្រូវដឹកជញ្ជូន និងត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យាធានារ៉ាប់រងនេះក្នុងអំឡុងពេលដែលបានបញ្ជាក់ខាងលើ ។ ប្រសិនបើចំនួនទឹកប្រាក់ពិតប្រាកដ ខុសពីចំនួនទឹកប្រាក់ដែលត្រូវបានប៉ាន់ស្មាន ដែលតាមរយៈនេះបុព្វលាភធានារ៉ាប់រងត្រូវបានបង់ ភាពខុសគ្នានៃបុព្វលាភធានារ៉ាប់រងត្រូវបានកែតម្រូវដោយការបង់ប្រាក់តាមសមាមាត្របន្ថែមទៅឱ្យក្រុមហ៊ុន ឬតាមរយៈការបង្វិលសងនូវប្រាក់បុព្វលាភធានារ៉ាប់រងវិញដោយក្រុមហ៊ុនតាមករណីជាក់ស្តែង ។

៨. ប្រសិនបើនៅពេលមានការបាត់បង់ណាមួយដែលធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះ មានការធានារ៉ាប់រងផ្សេងទៀត ទោះក្នុងលក្ខណៈណាមួយក៏ដោយ ដោយធានាលើទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ទោះបីត្រូវបានអនុវត្តដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងក៏ដោយ ក្រុមហ៊ុនមិនត្រូវទទួលខុសត្រូវចំពោះការបង់ ឬរួមចំណែកបង់ឱ្យលើសពីសមាមាត្រដែលខ្លួនត្រូវបង់ចំពោះការបាត់បង់ទាំងនោះឡើយ ។

៩. បុគ្គលដែលត្រូវបានធានារ៉ាប់រង មិនត្រូវបង់ការចំណាយណាមួយក្នុងការប៉ះប៉ូវលើការខូចខាតណាមួយ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនឡើយ ហើយមិនត្រូវចរចា បង់ ដោះស្រាយ ទទួលស្គាល់ ឬបដិសេធនូវបណ្តឹងទាមទារសំណងណាមួយ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនឡើយ ។

១០. គ្មានចំណុចណាមួយនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ផ្តល់សិទ្ធិណាមួយប្រឆាំងនឹងក្រុមហ៊ុន ទៅឱ្យបុគ្គលណាមួយក្រៅពីបុគ្គលដែលត្រូវបានធានារ៉ាប់រងឡើយ ហើយក្រុមហ៊ុននឹងមិនត្រូវបានភ្ជាប់កាតព្វកិច្ច ដោយសារការផ្ទេរអត្ថប្រយោជន៍របស់បុគ្គលដែលត្រូវបានធានារ៉ាប់រងឡើយ លើកលែងតែដោយសារករណីទទួលមរណភាព និងលុះត្រាតែ ឬរហូតទាល់តែក្រុមហ៊ុនធ្វើការប្រកាសតាមរយៈបដ្ឋិលេខថា ការធានារ៉ាប់រងនោះនឹងត្រូវបានបន្ត ។

១១. ប្រសិនបើសំណើ ឬការប្រកាសរបស់បុគ្គលដែលត្រូវធានារ៉ាប់រងមិនពិតក្នុងទិដ្ឋភាពណាមួយ ឬប្រសិនបើការពិតជាក់ស្តែងណាមួយដែលប៉ះពាល់ដល់ហានិភ័យនោះ ត្រូវបានបង្ហាញដោយមិនត្រឹមត្រូវនៅក្នុងសំណើ ឬការប្រកាសនោះ ឬសំណើសុំបន្តការធានារ៉ាប់រងថ្មីណាមួយធ្វើឡើងតាមរយៈការផ្តល់ព័ត៌មានមិនពិត ឬការបង្ហាញព័ត៌មានមិនពិត ឬការផ្តល់ព័ត៌មានដោយបង្ខំ ឬប្រសិនបើការទាមទារសំណងណាមួយធ្វើឡើងតាមរយៈការក្លែងបន្លំ ឬត្រូវបានបំផ្លើស ឬប្រសិនបើការប្រកាស ឬការអះអាងមិនពិតណាមួយត្រូវបានធ្វើឡើងដើម្បីគាំទ្រដល់ការទាមទារសំណងទាំងនោះ នោះកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវចាត់ទុកជាអសារបង់ ។

១២. ប្រសិនបើមានវិវាទណាមួយកើតឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ក្រុមហ៊ុន យោងតាមកិច្ចសន្យាធានារ៉ាប់រងនេះវិវាទនោះដោយឯករាជ្យពីបញ្ហាផ្សេងទៀតទាំងអស់ ត្រូវយោងទៅលើការសម្រេចចិត្តដោយមជ្ឈត្តករដែលនឹងត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីទាំងពីរ ឬប្រសិនបើពួកគេមិនអាចព្រមព្រៀងគ្នាលើមជ្ឈត្តករម្នាក់ នោះការធ្វើសម្រេចចិត្តត្រូវផ្អែកលើមជ្ឈត្តករពីររូប ដែលម្នាក់ក្នុងចំណោមមជ្ឈត្តករទាំងពីររូបនោះត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗ និងក្នុងករណីមានការខ្វែងគំនិតគ្នារវាងមជ្ឈត្តករទាំងពីររូប នោះវិវាទនឹងត្រូវយោងទៅលើការសម្រេចចិត្តរបស់អ្នកវិនិច្ឆ័យមួយរូបទៀត ដែលត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរ ដោយមជ្ឈត្តករទាំងពីររូបមុនពេលធ្វើមជ្ឈត្តវិនិច្ឆ័យ ហើយសេចក្តីសម្រេចណាមួយដោយមជ្ឈត្តវិនិច្ឆ័យត្រូវជាលក្ខខណ្ឌដែលមានអាទិភាពលើសិទ្ធិចាត់វិធានការណាមួយប្រឆាំងនឹងក្រុមហ៊ុនពាក់ព័ន្ធនឹងវិវាទណាមួយ អំពីទំហំនៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ។

១៣. គ្មានករណីណាដែលក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះការបង់សំណងណាមួយ បន្ទាប់ពីការផុតកំណត់រយៈពេលដប់ពីរខែ គិតចាប់ពីមានការ

បាត់បង់នោះឡើយលុះត្រាតែការទាមទារនោះជាកម្មវត្ថុនៃការវង់ចាំវិធានការរបស់តុលាការ ឬមជ្ឈត្តវិនិច្ឆ័យ ។

១៤. ការគោរពនិងអនុវត្តតាមយ៉ាងត្រឹមត្រូវនូវ ខចែង បញ្ញត្តិ លក្ខខណ្ឌ និងបដ្ឋិលេខនៃកិច្ចសន្យាធានារ៉ាប់រងនេះដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងកម្រិតដែលវាមានការពាក់ព័ន្ធនឹងចំណុចដែលខ្លួនត្រូវធ្វើ ឬគោរពតាមហើយភាពពិតប្រាកដនៃសេចក្តីប្រកាសអះអាង និងចម្លើយនៅក្នុងសំណើដែលបានលើកឡើងគឺជាលក្ខខណ្ឌជាមុននៃការទទួលខុសត្រូវរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណងយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ។

១៥. ក្រុមហ៊ុនមិនទទួលខុសត្រូវឡើយចំពោះការបាត់បង់ ឬការខូចខាតណាមួយដែលបង្កឡើងដោយ ឬកើតឡើងដោយសារតែសកម្មភាពនៃការឆបោករបស់បុគ្គលណាមួយ នៅក្នុងអត្ថន័យនៃនិយមន័យបទល្មើសឆបោកដូចខាងក្រោម ។

"ជនណាដែលតាមរយៈការបោកបន្លំជនណាម្នាក់ទៀត បើទោះជាអំពើបន្លំនោះជាការបញ្ឆុះបញ្ឆូលតែម៉្យាង ឬជាអំពើចំបងមួយ ឬមិនមែនក៏ដោយការបញ្ឆុះបញ្ឆូលដោយបន្លំ ឬដោយមិនស្មោះត្រង់ជនណាម្នាក់ទៀតឱ្យចាញ់បោកព្រមប្រគល់ទ្រព្យសម្បត្តិណាមួយទៅឱ្យជនណាម្នាក់ ឬព្រមព្រៀងឱ្យជនម្នាក់នោះរក្សាទ្រព្យសម្បត្តិនោះទុក ឬបញ្ឆុះបញ្ឆូលដោយចេតនាជនណាម្នាក់ឱ្យចាញ់បោកព្រមធ្វើអំពើ ឬមិនធ្វើអំពើណាមួយដែលជននោះនឹងមិនធ្វើ ឬមិនខកខានធ្វើឡើយ ប្រសិនបើខ្លួនពុំត្រូវបានគេបោកបន្លំទេនោះ ហើយដែលអំពើ ឬការមិនធ្វើអំពើនោះបង្កឱ្យមាន ឬអាចបង្កឱ្យមានការខូចខាតឬបង្កគ្រោះថ្នាក់ដល់បុគ្គលដទៃទៀតទាំងផ្លូវកាយ ផ្លូវចិត្ត កេរ្តិ៍ឈ្មោះ ឬទ្រព្យសម្បត្តិឱ្យឈ្មោះថា អំពើឆបោក" ។

១៦. ក្រុមហ៊ុនមិនទទួលខុសត្រូវឡើយចំពោះការបាត់បង់ ឬការខូចខាតណាមួយដែលបង្កឡើង ឬកើតឡើងដោយសារ តែសកម្មភាពមិនស្របច្បាប់នៃការរំលោភលើសេចក្តីទុកចិត្តដោយបុគ្គលណាមួយនៅក្នុងអត្ថន័យនៃនិយមន័យបទល្មើសរំលោភលើសេចក្តីទុកចិត្ត ដែលជាបទឧក្រិដ្ឋដូចខាងក្រោម ។

"ជនណាក៏ដោយ ដែលត្រូវបានផ្តល់ឱ្យនូវទ្រព្យសម្បត្តិក្នុងលក្ខណៈណាមួយ ឬនូវអំណាចគ្រប់គ្រងលើទ្រព្យសម្បត្តិ ដោយយក ឬផ្លាស់ប្តូរទ្រព្យសម្បត្តិនោះដោយភាពមិនស្មោះត្រង់ឱ្យទៅជាការប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ ឬបោះបង់ដោយភាពមិនស្មោះត្រង់នូវទ្រព្យសម្បត្តិនោះ ដោយរំលោភលើវិធានច្បាប់ដែលបញ្ញត្តិពីរបៀបដោះបន្ទុកលើការផ្ញើទុកនោះ ឬរំលោភលើកិច្ចសន្យាតាមផ្លូវច្បាប់ដោយជាក់លាក់ ឬដោយតុណ្ហីភាពដែលអនុញ្ញាតអោយខ្លួនរួចបន្ទុកពីការផ្ញើទុកនោះ ឬដោយចេតនាបង្កឱ្យបុគ្គលដទៃទទួលរងនូវការខូចខាតដោយអំពើខាងលើ ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសរំលោភលើសេចក្តីទុកចិត្ត" ។

**លក្ខខណ្ឌធានាចំពោះបុព្វលាភធានារ៉ាប់រង**

នេះជាលក្ខខណ្ឌមូលដ្ឋាននិងពិសេសបំផុតនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលបុព្វលាភធានារ៉ាប់រងត្រូវតែបង់ និងទទួលបានដោយក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រងនេះ /បដ្ឋិលេខ/វិញ្ញាបនបត្របន្តកិច្ចសន្យាធានារ៉ាប់រងថ្មី។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេនោះកិច្ចសន្យានេះត្រូវបានបញ្ឈប់ដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភធានារ៉ាប់រងតាមសមាមាត្រសម្រាប់រយៈពេលដែលខ្លួនស្ថិតនៅក្នុងហានិភ័យ ។

នៅពេលដែលបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ស្របតាមការធានានេះត្រូវបានទទួលដោយភ្នាក់ងារមានការអនុញ្ញាតរបស់ក្រុមហ៊ុន ប្រាក់នេះត្រូវចាត់ទុកថាបានទទួលដោយក្រុមហ៊ុនសម្រាប់គោលបំណងនៃការធានានេះ ហើយកាតព្វកិច្ចក្នុងការបង្ហាញថាបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ ត្រូវបានទទួលដោយបុគ្គលម្នាក់រួមទាំងភ្នាក់ងារធានារ៉ាប់រង ដែលមិនត្រូវបានអនុញ្ញាតឱ្យទទួលបុព្វលាភធានារ៉ាប់រងនោះ ត្រូវធ្លាក់ទៅលើក្រុមហ៊ុន។

រាល់លក្ខខណ្ឌនិង ខ ចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ ។

**ខ ចែងស្តីពីប្រព័ន្ធព័តិមានវិទ្យា**

ការខូចខាតទ្រព្យសម្បត្តិដែលត្រូវធ្វើសំណងស្របតាមការធានារ៉ាប់រងនេះ សំដៅដល់ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិ។ ការខូចខាតផ្នែករូបវន្តនៃលក្ខណៈសំខាន់របស់ទ្រព្យសម្បត្តិមិនរាប់បញ្ចូលការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រឡើយ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបង្កឡើងដោយការលុប ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម ។

ដោយហេតុនេះ ចំណុចខាងក្រោមនេះ ត្រូវបានលើកលែងពីការធានារ៉ាប់រងនេះ :

(ក) ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ជាពិសេសការផ្លាស់ប្តូរមិនល្អនៅក្នុងទិន្នន័យ ឬកម្មវិធីកុំព្យូទ័រដែលបណ្តាលមកពីការលុបចោល ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម និងការបាត់បង់ដោយសារការផ្អាកអាជីវកម្មដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ។ ទោះបីជាមានការលើកលែងនេះក៏ដោយ ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ ដែលជាលទ្ធផលដោយផ្ទាល់នៃការខូចខាតផ្នែករូបវន្តដែលមានការធានារ៉ាប់រងដល់លក្ខណៈសំខាន់នៃទ្រព្យសម្បត្តិត្រូវបានធ្វើសំណង។

(ខ) ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីភាពអន់ថយផ្នែកមុខងារ ភាពអាចរកបាន កម្រិតនៃការប្រើប្រាស់ ឬភាពអាចបើកមើលបាននៃទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ដោយសារការផ្អាកអាជីវកម្មដែលបង្កឡើងដោយសារការបាត់បង់ ឬការខូចខាតនោះ ។

**បដិលេខលើកលែងករណីភេរវកម្ម**
ទោះបីជាមានបទប្បញ្ញត្តិណាមួយផ្ទុយទៅនឹងការធានារ៉ាប់រងនេះ ឬបដិលេខបន្ថែមណាមួយក៏ដោយ វាជាការព្រមព្រៀងគ្នាថា ការធានារ៉ាប់រងនេះមិនរួមបញ្ចូល ការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយ ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពី ឬពាក់ព័ន្ធនឹងសកម្មភាពភេរវកម្មណាមួយ ដោយមិនគិតពីបុព្វហេតុ ឬព្រឹត្តិការណ៍ណាមួយផ្សេងទៀត ដែលរួមចំណែករួមគ្នា ឬជាលទ្ធផលបង្កឱ្យមានការបាត់បង់នោះ ។

សម្រាប់គោលបំណងនៃបដិលេខនេះ សកម្មភាពភេរវកម្មសំដៅលើសកម្មភាពមួយដែលមានជាអាទិ៍ដូចជា ការប្រើកម្លាំង ឬអំពើហិង្សា និង/ឬ ការគំរាម-កំហែងប្រើកម្លាំង ឬអំពើហិង្សារបស់បុគ្គលណាមួយ ឬក្រុមណាមួយបើទោះបីជាប្រព្រឹត្តតែម្នាក់ឯង ឬក្នុងនាម ឬពាក់ព័ន្ធនឹងអង្គភាពណាមួយ ឬរដ្ឋាភិបាលសម្រាប់គោលបំណងនយោបាយ សាសនា មនោគមវិជ្ជា ឬគោលបំណងស្រដៀងគ្នានេះ ដែលរួមមានចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬដើម្បីបង្កការភ័យខ្លាចដល់សាធារណជន ឬក្រុមណាមួយនៃសាធារណជននោះ ។

បដិលេខនេះ មិនរួមបញ្ចូលផងដែរនូវការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយអ្វីក៏ដោយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោលដែលកើតឡើងមកពី ឬពាក់ព័ន្ធនឹងការចាត់វិធានការណាមួយដើម្បីគ្រប់គ្រង ទប់ស្កាត់ បង្ក្រាប ឬទាក់ទងនឹងសកម្មភាពភេរវកម្មតាមវិធីណាមួយ ។

ប្រសិនបើក្រុមហ៊ុនចោទប្រកាន់ថា តាមរយៈហេតុផលនៃការលើកលែងនេះ ការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយ មិនត្រូវបានធានារ៉ាប់រងដោយកិច្ចសន្យាធានារ៉ាប់រងនេះ បន្ទុកនៃការបញ្ជាក់អ្វីដែលផ្ទុយត្រូវធ្លាក់លើបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

ក្នុងករណីដែលផ្នែកណាមួយនៃបដិលេខនេះ ត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន ផ្នែកផ្សេងទៀតដែលនៅសល់នៅតែស្ថិតនៅជាធរមាន និងមានសុពលភាពពេញលេញ ។
NMA2921
០៨/១០/២០០១

**ខចែងស្តីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង** (LMA 3100)
គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រងនិងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយ ដែលការផ្តល់សំណង ឬអត្ថប្រយោជន៍ទាំងនោះធ្វើអោយក្រុមហ៊ុនធានារ៉ាប់រងប្រឈមមុខនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយតកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ។